00658616

ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 05 / 04 / 2011
ម៉ោង (Time/Heure) : 09:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E51/7



**អង្គជំនុំជម្រះសាលាដំបូង**

**ជូនចំពោះ: ភាគីទាំងអស់នៃសំណុំរឿង ០០២** កាលបរិច្ឆេទ: ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១

**ពី: ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន: លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង,មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ: សេចក្ដីណែនាំដល់ភាគីពាក់ព័ន្ធនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ**

ដោយយោងទៅលើសេចក្ដីណែនាំកន្លងមករបស់អង្គជំនុំជម្រះ (ឯកសារលេខ E35, E51, E51/5, E51/5/3 និង E51/6) ដែលបានបញ្ជាក់ថា ភាគីត្រូវដាក់សំណើសុំពាក់ព័ន្ធនឹងបញ្ហាអញ្ញត្រកម្ម និងចម្លើយតបដោយសង្ខេបខ្លីៗ នៅដំណាក់កាលដំបូង។ អង្គជំនុំជម្រះក៏សូមផ្ដល់ការណែនាំដល់ភាគី នាពេលសមស្របពាក់ព័ន្ធនឹងការតម្រូវឱ្យដាក់សារណាបន្ថែមទៀត ដូចជាការកំណត់ពេលសម្រាប់ការធ្វើសំអាងហេតុផ្ទាល់មាត់ និងរយៈពេល និងលក្ខខណ្ឌនានាក្នុងការសម្រេចលើអញ្ញត្រកម្មទាំងអស់។

នៅពេលនេះ ក្រុមមេធាវីការពារក្ដីនីមួយៗបានដាក់អញ្ញត្រកម្មរបស់ខ្លួនរួចរាល់ហើយ។ ចំណែកសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីក៏បានដាក់ចម្លើយតបរបស់ខ្លួនរួចហើយដែរ។ ដូច្នេះ អង្គជំនុំជម្រះសូមផ្ដល់ការណែនាំដូចខាងក្រោម ពាក់ព័ន្ធនឹងអញ្ញត្រកម្មទាំងអស់ដែលអង្គជំនុំជម្រះបានទទួល អនុលោមតាមសេចក្ដីណែនាំកន្លងមករបស់អង្គជំនុំជម្រះ។

១. <u>បទល្មើសតាមច្បាប់ជាតិ (ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៥៦) (នួន ជា, ខៀវ សំផន, អៀង ធីរិទ្ធ និង អៀង សារី)</u>

អង្គជំនុំជម្រះសូមរំលឹកឡើងវិញអំពីសេចក្ដីសម្រេចរបស់ខ្លួនចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ស្ដីពីអញ្ញត្រកម្ម ពាក់ព័ន្ធនឹងបទល្មើសតាមច្បាប់ជាតិអំពីមនុស្សឃាតគិតទុកជាមុន និងការធ្វើទារុណកម្ម នៅក្នុងសំណុំរឿង ០០១។ នៅក្នុងសេចក្ដីសម្រេចនោះ អង្គជំនុំជម្រះពុំបានឈានទៅដល់ការសម្រេចថាតើអាជ្ញាយុកាលនៃបទល្មើសបានរាំងដល់ការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ ឬយ៉ាងណានោះទេ។ នៅក្នុងចម្លើយតបរួម

របស់ខ្លួនទៅនឹងអញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ របស់ក្រុមមេធាវីការពារក្តីចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ (E51/5/3/1) សហព្រះរាជអាជ្ញាបានអះអាងថា អាជ្ញាយុកាលនៃបទល្មើសជាតិមិនផុតរលត់នៅឡើយទេសម្រាប់ការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទទាំងអស់នៅក្នុងសំណុំរឿង ០០២។ សហព្រះរាជអាជ្ញាបានគូសបញ្ជាក់ផងដែរអំពីចេតនារបស់ខ្លួន ក្នុងការលើកយកភស្តុតាងទៅបង្ហាញនៅពេលសវនាការដើម្បីបញ្ជាក់ថា ពុំមានលទ្ធភាពសមស្របណាមួយ ដើម្បីចោទប្រកាន់ជនជាប់ចោទទាំងបួនមុនពេលពួកគេចុះចូលជាមួយរដ្ឋាភិបាលកម្ពុជានៅឆ្នាំ ១៩៩៦ និង ១៩៩៨ ឡើយ។ ដូច្នេះហើយអាជ្ញាយុកាលនៃបទល្មើសជាតិពុំត្រូវបានរាប់រហូតដល់ឆ្នាំ ១៩៩៦ និងឆ្នាំ ១៩៩៨។ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចលើបញ្ហានេះ ដំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី។ អង្គជំនុំជម្រះសាលាដំបូង យល់ស្របជាមួយក្រុមមេធាវីការពារក្តីដែលថា ត្រូវសម្រេចលើអញ្ញត្រកម្មនេះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ដូច្នេះ អង្គជំនុំជម្រះសូមស្នើឱ្យសហព្រះរាជអាជ្ញា ដាក់សារណា ដែលបញ្ជាក់អំពីមូលដ្ឋាននៃអំណះអំណាងរបស់ខ្លួនដែលថា បទល្មើសតាមច្បាប់ជាតិមិនត្រូវបានរារាំងដោយអាជ្ញាយុកាល ពាក់ព័ន្ធនឹងជនជាប់ចោទទាំងអស់ក្នុងសំណុំរឿង ០០២ មិនឱ្យហួសពីថ្ងៃ សុក្រ ទី ២៧ ខែ ឧសភា ឆ្នាំ ២០១១ និងមិនឱ្យលើសពី ៣០ ទំព័រជាភាសាខ្មែរ (ដោយភ្ជាប់មកជាមួយនូវឯកសារភស្តុតាងផ្សេងៗ ឬលេខយោងសំណុំរឿង)។ ពេលកំណត់សម្រាប់ក្រុម មេធាវីការពារក្តីឆ្លើយតបទៅនឹងសារណារបស់សហព្រះរាជអាជ្ញាគឺថ្ងៃ សុក្រ ទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។ ក្រុមមេធាវីការពារក្តីនីមួយៗត្រូវបានអនុញ្ញាតឱ្យសរសេរចម្លើយតបរបស់ខ្លួនចំនួន ១០ ទំព័រជាភាសាខ្មែរ (ឬ ៣០ ទំព័រ ជា ភាសាខ្មែរ ប្រសិនបើក្រុមមេធាវីការពារក្តីជ្រើសរើសការសរសេរចម្លើយតបរួម)។

## ២. <u>បទល្មើសតាមច្បាប់អន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវ (រួមទាំងគោលការណ៍នីត្យានុកូលភាព អាជ្ញាយុកាលនៃបទល្មើស និងយុត្តាធិការតាមបទល្មើស) (ខៀវ សំផន, នួន ជា, អៀង ធីរិទ្ធ និង អៀង សារី)</u>

អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងអំឡុងពេលបច្ចុប្បន្ននេះ ភាគីមិនចាំបាច់ដាក់សារណាជាលាយលក្ខណ៍បន្ថែមពាក់ព័ន្ធនឹងអញ្ញត្រកម្មទាំងអស់នេះឡើយ ពោលគឺដើម្បីត្រៀមទុកពេលវេលានៅពេលភាគីស្នើសុំសារណាបន្ថែមណាមួយ បន្ទាប់ពី អ.ប.ជ ចេញសំអាងហេតុនៅពេលខាងមុខពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ទាំងអស់ដែលប្តឹងជំទាស់នឹងដីកាដំណោះស្រាយ។ នៅក្នុងករណីដែលភាគីណាមួយស្នើសុំសារណាបន្ថែម អង្គជំនុំជម្រះនឹងស្នើឱ្យក្រុមទាំងអស់កំណត់ឱ្យបានច្បាស់លាស់នូវផ្នែកនៃសំអាងហេតុទាំងឡាយណាដែលសារណាបន្ថែមនោះលើកឡើង មិនឱ្យលើសពី ១០ ទំព័រជាភាសាខ្មែរ និងក្នុងរយៈពេលបីសប្តាហ៍ គិតចាប់ពី

ថ្ងៃនេះ ឬថ្ងៃដែល អ.ប.ជ ចេញសំអាងហេតុ (ទៅតាមករណីជាក់ស្ដែង)។ បន្ទាប់មកទៀត អង្គជំនុំជម្រះនឹងចេញសេចក្ដីណែនាំបន្ថែមទៀតពាក់ព័ន្ធនឹងសារណាទាំងអស់នេះ ទៅតាមពេលសមស្រប។ ភាគីនឹងមានឱកាសលើកឡើងនូវទឡ្ហីករណ៍ផ្ទាល់មាត់ពាក់ព័ន្ធនឹងអញ្ញត្រកម្មទាំងនេះនៅពេលសវនាការបឋម។

៣. <u>ការលើកលែងទោស និងការអនុគ្រោះទោស (អៀង សារី)</u>

ដោយបានពិចារណាលើសារណារបស់អៀង សារី មកទល់ថ្ងៃនេះ (ឯកសារលេខ E51/4 និង E43) អង្គជំនុំ-ជម្រះនឹងអនុញ្ញាតឱ្យក្រុមមេធាវីការពារក្ដី អៀង សារី ដាក់សារណាបន្ថែមស្ដីពីបញ្ហាខាងលើមិនឱ្យលើសពី ៣០ ទំព័រជាភាសាខ្មែរ នៅពេលក្រោយ ប្រសិនបើមេធាវីការក្ដីមានបំណង។ អង្គជំនុំជម្រះនឹងជូនដំណឹងអំពីពេលកំណត់ឱ្យក្រុមមេធាវីការពារក្ដី បានដឹងនៅពេលក្រោយ បន្ថែមពីលើពេលកំណត់ពាក់ព័ន្ធនឹងចម្លើយតបនានាដើម្បីឱ្យខ្លួនមានលទ្ធភាពដាក់បញ្ចូលនូវសារណាបន្ថែមណាមួយដែលចាំបាច់ នៅពេលសំអាងហេតុត្រូវបានផ្ដល់ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ។ ភាគីនឹងមានឱកាសលើកឡើងនូវទឡ្ហីករណ៍ផ្ទាល់មាត់ពាក់ព័ន្ធនឹងអញ្ញត្រកម្មទាំងនេះនៅពេលសវនាការបឋម។

៤. <u>ការហាមឃាត់ទល់នឹងការកាត់ទោសច្រើនដងចំពោះបទល្មើសតែមួយ *(គោលការណ៍គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ Non bis in idem)* (អៀង សារី)</u>

ដោយបានពិចារណាលើសារណារបស់អៀង សារី មកទល់ថ្ងៃនេះ (ឯកសារលេខ E51/4 និង E43) អង្គជំនុំ-ជម្រះនឹងអនុញ្ញាតឱ្យក្រុមមេធាវីការពារក្ដី អៀង សារី ដាក់សារណាបន្ថែមស្ដីពីបញ្ហាខាងលើមិនឱ្យលើសពី ៣០ ទំព័រជាភាសាខ្មែរ ប្រសិនបើខ្លួនចង់ធ្វើដូច្នេះ។ អង្គជំនុំជម្រះនឹងជូនដំណឹងអំពីពេលកំណត់ឱ្យក្រុមមេធាវីការពារក្ដីបានដឹងនៅពេលក្រោយ បន្ថែមពីលើពេលកំណត់ពាក់ព័ន្ធនឹងចម្លើយតបនានា ដើម្បីឱ្យខ្លួនមានលទ្ធភាពដាក់បញ្ចូលនូវសារណាបន្ថែមណាមួយដែលចាំបាច់ នៅពេលសំអាងហេតុត្រូវបានផ្ដល់ពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ។ ភាគីនឹងមានឱកាសលើកឡើងនូវទឡ្ហីករណ៍ផ្ទាល់មាត់ពាក់ព័ន្ធនឹងអញ្ញត្រកម្មទាំងនេះនៅពេលសវនាការបឋម។

<u>៥. យុត្តាធិការលើរូបបុគ្គល (ខៀវ សំផន)</u>

ដំណោះស្រាយចំពោះសំណួរនេះបង្ហាញពីការវាយតម្លៃរួមចូលគ្នាមួយទៅលើ អង្គហេតុនិងអង្គច្បាប់។ ដោយហេតុនេះ ការសំអាងហេតុដោយផ្ទាល់មាត់នឹងមិនមាននៅក្នុងសវនាការបឋមឡើយ ប៉ុន្តែនឹងត្រូវគ្រោងធ្វើនៅដំណាក់កាលដំបូងនៃសវនាការ ពោលគឺបន្ទាប់ពីសវនាការស្តីពីភស្តុតាងទាក់ទងនឹងតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទទាំងបួន។ អង្គជំនុំជម្រះមិនតម្រូវឱ្យមានការដាក់សារណាជាលាយលក្ខណ៍អក្សរ ឬការឆ្លើយតបជាលាយលក្ខណ៍អក្សរថែមទៀតទេនៅដំណាក់កាលនេះទេ។ ការណែនាំបន្ថែមទៀតពាក់ព័ន្ធនឹងការកំណត់ពេលវេលានៃការលើកសំអាងហេតុផ្ទាល់មាត់ទាំងនេះនឹងធ្វើឡើងជាបន្តបន្ទាប់តាមពេលវេលាសមស្រប។

<u>បញ្ហាផ្សេងទៀត</u>

អង្គជំនុំជម្រះយល់ឃើញថា បញ្ហាខាងក្រោមដែលត្រូវបានលើកឡើងនេះគឺមិនស្ថិតនៅក្រោមវិសាលភាពវិធាន ៨៩ នៃវិធានផ្ទៃក្នុងទេ។

*ក. ការភាន់ច្រឡំនៅក្នុងដំណើរការស៊ើបអង្កេតតាមផ្លូវច្បាប់ មោឃភាពតាមការចោទប្រកាន់ និងការរំលោភលើសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌* (នួន ជា)។
ខ. *ការចោទប្រកាន់អំពីការជ្រៀតជ្រែកផ្នែកនយោបាយ* (នួន ជា)។ អង្គជំនុំជម្រះយល់ថាការចោទប្រកាន់នេះពុំមានទម្ងន់គ្រប់គ្រាន់ជាអញ្ញត្រកម្មនៅក្នុងអត្ថន័យនៃវិធាន ៨៩ ឡើយ។
គ. *វិធានផ្ទៃក្នុង អ.វ.ត.ក*។

អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចមួយដោយមានសំអាងហេតុ ជាការឆ្លើយតបនឹងសំណើសុំនេះក្នុងពេលវេលាសមស្រប។